# ប្រជាជនកម្ពុជាដឹងពីរបៀបសម្តែងមតិរបស់ខ្លួន - សេរីភាពនៃការសម្តែងមតិ និងការជួបជុំនៅព្រះរាជាណាចក្រអេចូរិយៈ

***ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR Cambodia) បានជួយបង្កើនការយល់ដឹងគួរឲ្យកត់សម្គាល់ អំពីសេរីភាពក្នុងការសម្តែងមតិ និងការជួបជុំ ដែលក្នុងឆ្នាំ២០១៣ បាននាំឲ្យមានការបោះឆ្នោតមួយប្រកបដោយថាមវន្ត និងមានការសម្តែងមតិច្រើន***



បាតុកម្មនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៣

នៅឆ្នាំបន្ទាប់ពីមានការបោះឆ្នោតសកលក្នុងខែកក្កដា ឆ្នាំ ២០១៣ មក កម្ពុជាបានជួបស្ថានការណ៍គួរឲ្យភ្ញាក់ផ្អើលមួយខាងនយោបាយ ដែលនៅពេលនោះ បើតាមការប៉ាន់ស្មានរបស់រដ្ឋាភិបាល មានបាតុកម្មប្រមាណជា ៨៥០ លើក បានធ្វើឡើងនៅទូទាំងប្រទេស។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ប្រចាំកម្ពុជាបានចូលរួមចំណែកក្នុងការធ្វើឲ្យសម្រេចបានកាន់តែច្រើនថែមទៀតនូវសេរីភាពក្នុងការការសម្តែងមតិ និងការជួបជុំដោយសន្តិវិធី តាមរយៈសកម្មភាពផ្សេងៗគ្នាជាច្រើន ដើម្បីលើកស្ទួយ និងការពារសិទ្ធិទាំងនេះ។

> "មានការផ្លាស់ប្តូរឥរិយាបទក្នុងប្រទេសនេះ ការភ្ញាក់រលឹកយល់ដឹងពីរឿងនយោបាយ ដែលតាមរយៈនេះ ប្រជាពលរដ្ឋបានយល់ដឹងពីសិទ្ធិរបស់ខ្លួន ក្នុងការបញ្ចេញមតិ និងការជួបជុំ និងងើបឈរឡើង ទាមទារសិទ្ធិទាំងនោះ។ ការិយាល័យ OHCHR បានដើរតួទាទីដ៏សំខាន់បំផុតមួយ ឈានសម្រេចគោលដៅនេះ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការសង្គមស៊ីវិលនៅតាមមូលដ្ឋាន តាមរយៈសកម្មភាពបណ្តុះបណ្តាល និងផ្សព្វផ្សាយអស់ពេលជាច្រើនឆ្នាំ ដើម្បីបង្កើនការយល់ដឹងនៅកម្ពុជាអំពីសិទ្ធិសេរីភាពក្នុងការសម្តែងមតិ និងការជួបជុំ"។
> - លោក អ៊ូ វីរៈ ប្រធានក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានមានប្រសាសន៍ដូច្នេះ។

ទំនាក់ទំនងជាប្រពៃណីរវាងរដ្ឋាភិបាល និង ប្រជាជននៅកម្ពុជា តែងតែមានលក្ខណៈស្រដៀងគ្នានឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ដោយមនុស្សសាមញ្ញមានករណីកិច្ចស្មើរតែដូចករណីកិច្ចជាកូនអញ្ចឹងដែរចំពោះរដ្ឋាភិបាល ដែលពួកគេមិនត្រូវនិយាយតវ៉ាឡើយ។ ឆ្នាំបន្ទាប់ពីការបោះឆ្នោត មានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវឥរិយាបទរបស់ប្រជាជនសាមញ្ញ ទាំងអ្នកគាំទ្ររដ្ឋាភិបាល ទាំងអ្នកប្រឆាំងនឹងរដ្ឋាភិបាល នេះបើនិយាយអំពីការទាមទារសិទ្ធិរបស់ខ្លួន។ កម្ពុជាបានឃើញចំនួននៃការប្រមូលផ្តុំជាសាធារណៈច្រើន ដែលមិនធ្លាប់មានពីមុនមក រាប់ទាំងការប្រមូលផ្តុំខាងនយោបាយ ការធ្វើកូដកម្មរបស់កម្មករ និងការតវ៉ារឿងទំនាស់ដីធ្លី និងបញ្ហាបរិស្ថាន។ ទន្ទឹមនឹងប្រតិកម្មរបស់អាជ្ញាធរចំពោះបាតុកម្មទាំងនោះមានការប្រែប្រួលក្តី ម្យ៉ាងវាបង្ហាញឲ្យឃើញពីការគោរពជាទូទៅដល់សេរីភាពក្នុងការជួបជុំក្នុងឆ្នាំ២០១៣ ហើយក្រោយមកមានការហាមប្រាមទាំងស្រុងដល់ការធ្វើបាតុកម្មក្នុងឆ្នាំ២០១៤ វាបង្ហាញឲ្យឃើញច្បាស់ថា ប្រជាជន

កម្ពុជាបានយល់ដឹងពីសិទ្ធិរបស់ខ្លួន ក្នុងការនិយាយតវ៉ា និងបង្ហាញពីកង្វល់របស់ខ្លួនឲ្យគេដឹងជាសាធារណៈ ហើយក្នុងឆ្នាំ២០១៣ នេះ ពួកគេបានព្យាយាមអនុវត្តសិទ្ធិទាំងនោះ ដែលចំនួនដង និងទ្រង់ទ្រាយធំបែបនេះ មិនធ្លាប់មានពីមុនមកទេ។

ក្នុងអំឡុងពេលពីរទសវត្សរ៍នេះ ចាប់តាំពីការបោះឆ្នោតក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៣ ដែលបានរៀបចំឡើងដោយ អ.ហ.ប មក អង្គការសិទ្ធិមនុស្សទាំងក្នុង និងក្រៅប្រទេស បានខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងពីទំនួលខុសត្រូវសិទ្ធិមនុស្សរបស់រដ្ឋាភិបាល រួមមាន សេរីភាព និងការជួបជុំដោយសន្តិវិធី ដល់ប្រជាពលរដ្ឋកម្ពុជា។ មានការផ្សព្វផ្សាយព័ត៌មានតាមវិធីជាច្រើន ដូចជា តាមវិទ្យុ ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព របាយការណ៍ជាលាយលក្ខណ៍អក្សរ សិប្បសាលា ហើយកាន់តែមានការកើនឡើងក្នុងឆ្នាំថ្មីៗកន្លងទៅនេះ តាមរយៈអ៊ីនធឺណិត។ ការផ្លាស់ប្តូរតវិយាបទក្នុងឆ្នាំកន្លងមក គឺដោយសារ មួយផ្នែកធំបានមកពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់តួអង្គសិទ្ធិមនុស្សនានាក្នុងប្រទេស រយៈពេលជាច្រើនឆ្នាំមកនេះ គួបផ្សំទៅនឹងប្រជាជនសាមញ្ញខ្លួនឯងផ្ទាល់ ដឹងពីរបៀបសម្តែងមតិរបស់ខ្លួន។

សកម្មភាពការងារដទៃផ្សេងទៀតរបស់ការិយាល័យ OHCHR ក្នុងការលើកស្ទួយ និងការពារសេរីភាពក្នុងការសម្តែងមតិ និងការជួបជុំដោយសន្តិវិធីនៅកម្ពុជា រួមមាន កម្មវិធីពិភាក្សាតាមវិទ្យុអំពីខ្លឹមសារនៃសិទ្ធិទាំងនេះការតាមឃ្លាំមើលបាតុកម្មផ្សេងៗ និងការផ្សព្វផ្សាយឯកសារជារូបភាព និងជាលាយលក្ខណ៍អក្សរ នៅទូទាំងប្រទេស។ ដើម្បីបន្តអនុវត្តច្បាប់ទាំងនេះដោយសន្តិវិធី ក្នុងឆ្នាំ២០០៩ ការិយាល័យ OHCHR បានបោះពុម្ពរួមគ្នាជាមួយក្រសួងមហាផ្ទៃនូវគោលការណ៍ណែនាំអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោសន្តិវិធី ដែលគូសបញ្ជាក់ពីសិទ្ធិរបស់ប្រជាពលរដ្ឋចំពោះសេរីភាពនៃការជួបជុំ និងការសម្តែងមតិ ព្រមទាំងតួនាទីនៃអ្នករៀបចំធ្វើបាតុកម្ម និងទំនួលខុសត្រូវរបស់អាជ្ញាធរស្របតាមច្បាប់។ គោលការណ៍ណែនាំអនុវត្តរៀបរាប់លម្អិតពីលក្ខណ្ឌតម្រូវពីនីតិវិធីក្នុងការរៀបចំធ្វើបាតុកម្ម។ ជាច្រើនឆ្នាំកន្លងទៅនេះ ការិយាល័យ OHCHR ប្រចាំកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលយ៉ាងទូលំទូលាយស្តីពីច្បាប់ និងគោលការណ៍ណែនាំអនុវត្ត ដល់តំណាងសង្គមស៊ីវិលរាប់រយនាក់ រាប់ទាំង បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល មេដឹកនាំសហជីពកម្មករ សកម្មជនសហគមន៍ អ្នកតស៊ូមតិលើសិទ្ធិ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) និងអ្នកសារព័ត៌មាន ដើម្បីជួយដល់អ្នកដែលរៀបចំធ្វើបាតុកម្មដោយសន្តិវិធីទាំងអស់នោះ ឲ្យគោរពតាមច្បាប់ក្នុងការរៀបចំធ្វើបាតុកម្មនេះ ហើយតាមរយៈការគោរពតាមច្បាប់នេះ វាអាចជួយកាត់បន្ថយហានីភ័យនៃការចាប់ខ្លួន។ ប្រជាជនកម្ពុជាកត់សម្គាល់ថា សព្វថ្ងៃនេះ ប្រទេសរបស់ខ្លួន មានភាពខុសគ្នាទាំងស្រុង ពីអ្វីដែលមានត្រឹមតែពីរឆ្នាំកន្លងទៅនេះ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋមានការសម្តែងមតិច្រើន។ ប្រព័ន្ធដ៏រឹងមាំមួយក្នុងការការពារសិទ្ធិមនុស្ស តម្រូវឲ្យមានកម្រិតយល់ដឹងច្បាស់លាស់ ទាំងអ្នកកាន់ភារកិច្ចចំពោះភារកិច្ចរបស់ខ្លួនក្នុងការលើកស្ទួយសិទ្ធិមនុស្ស ទាំងអ្នកអនុវត្តសិទ្ធិក្នុងការទាមទារសិទ្ធិទាំងនោះ។ ប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកអនុវត្តសិទ្ធិ បច្ចុប្បន្ននេះ បានបង្ហាញគ្រប់គ្រាន់ថាពួកគេមានសមត្ថភាពបំពេញសិទ្ធិមួយផ្នែករបស់ខ្លួនហើយ។ តាមរយៈការទាមទាមឥតឈប់ឈរ របស់ពួកគេ ឲ្យមានដំណោះស្រាយ យុត្តិធម៌ និងគណនេយ្យភាពនោះ ពួកគេជាគន្លឹះមួយដែលនឹងធានាថានៅទីបំផុត ប្រទេសនេះនឹងក្លាយទៅជាប្រទេសមួយដែលគោរព ការពារ និងលើកស្ទួយសិទ្ធិមនុស្សយ៉ាងពេញលេញ។

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia